ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**"រ.ទ.ស.ភ"**


លេខ ២២២.ស.ជ.ល

ភ្នំពេញ, ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧

**លិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា**
**ផ្គត់ផ្គង់វិក្កយបត្រថ្លៃទឹកនៅនឹងកន្លែង** Preprinted Thermal Bill

ខ្ញុំមានកិត្តិយសជម្រាបលោកប្រធានក្រុមហ៊ុន **អ៊ីបផ្លាយ កុំព្យូទ័រ ភ្នំពេញ** ថា ៖ ក្រោយពីការវាយតម្លៃលើឯកសារដាក់ដេញថ្លៃពីគ្រប់ក្រុមហ៊ុន ដែលបានបើកជាសាធារណៈកាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ដើម្បីផ្គត់ផ្គង់វិក្កយបត្រថ្លៃទឹកនៅនឹងកន្លែង Preprinted Thermal Bill រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានសម្រេចប្រគល់កិច្ចសន្យាជូនទៅក្រុមហ៊ុន **អ៊ីបផ្លាយ កុំព្យូទ័រ ភ្នំពេញ** ក្នុងតម្លៃកិច្ចសន្យាចំនួន **៣៣៤,៣៩៤,៥០០រៀល (បីរយសាមសិបបួនលានបីរយកៅសិបបួនពាន់ប្រាំរយរៀលគត់)**។ ក្រុមហ៊ុនត្រូវតែផ្គត់ផ្គង់ក្រដាស់សម្រាប់បោះពុម្ពវិក្កយបត្រថ្លៃទឹកនៅនឹងកន្លែងដែលមានពណ៌"ស" និងមិនប្រែពណ៌ ពេលត្រូវប្រេង ឬទឹក ព្រមទាំងមិនរលុបក្នុងរយៈពេលយ៉ាងតិច៣ខែក្រោមកំដៅ៤០ដឺក្រេ។

គំរូវិក្កយបត្រថ្លៃទឹកដែលត្រូវបោះពុម្ព (Preprint) មានភ្ជាប់មកជាមួយ។

អាស្រ័យហេតុនេះ សូមលោកប្រធានពិនិត្យ និងចុះហត្ថលេខាលើកិច្ចសន្យា ដែលបានជូនភ្ជាប់ រួចប្រគល់មករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយមានភ្ជាប់មកជាមួយនូវប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យា (Performance Security) ដោយអនុលោមទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា ក្នុងអំឡុងពេលមិនលើសពី១៥ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យានេះ។

សូមលោកប្រធានទទួលយកនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**បណ្ឌិត.ជា វិសុទ្ធ**

ចម្លងជូន៖
-ក្រុមហ៊ុន អ អិម អេ (ខេមបូឌា)
-ក្រុមហ៊ុន អាយធី-ស៊ីលូសិន (ខេមបូឌា)